THE SCHOOL DISTRICT OF PHILADELPHIA

**ស្នងការដ្ឋាន**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
ស្នងការ

12 មីនា 2021

ជូនចំពោះក្រុមគ្រួសារជាទីរាប់អាន

នៅសប្តាហ៍ក្រោយ មណ្ឌលសិក្សាធិការនឹងបើកកិច្ចដំណើរការជ្រើសរើសគំរូការសិក្សារបស់ខ្លួនម្តងទៀត ដែលអនុញ្ញាតឲ្យក្រុមគ្រួសារសិស្សានុសិស្សថ្នាក់មុនមត្តេយ្យសិក្សាកម្រិត 2 ដែលពីដំបូងបានជ្រើសរើសគំរូការសិក្សាតាមប្រព័ន្ធឌីជីថល 100% នៅរដូវស្លឹកឈើជ្រុះ ឲ្យមានឱកាសជ្រើសរើសយកការសិក្សាតាមបែបចម្រុះ (ការរួមបញ្ចូលគ្នារវាងការសិក្សាដោយផ្ទាល់ និងការសិក្សាតាមប្រព័ន្ធឌីជីថល តាមសប្តាហ៍នីមួយៗ) ក្នុងឆ្នាំសិក្សានេះ។

**ចន្លោះពេលជ្រើសរើសនឹងបើកនៅថ្ងៃអង្គារ ទី16 ខែមីនា និងបិទនៅថ្ងៃអង្គារ ទី23 ខែមីនា។** ស្រដៀងនឹងកិច្ចដំណើរការជ្រើសរើសកាលពីរដូវស្លឹកឈើជ្រុះទៅមិញដែរ គ្រួសារសិស្សានុសិស្សថ្នាក់មុនមត្តេយ្យសិក្សាកម្រិត 2 នឹងអាចជ្រើសរើសបានរវាងគំរូការសិក្សាបែបចម្រុះ និងគំរូការសិក្សាតាមប្រព័ន្ធឌីជីថល 100% គឺមួយណាដែលល្អបំផុតដោយពិចារណាទៅលើតម្រូវការកូន និងគ្រួសាររបស់អ្នក។ ប្រសិនបើអ្នកជ្រើសរើសការសិក្សាបែបចម្រុះ កូនរបស់អ្នកនឹងត្រូវមករៀននៅសាលារៀនដោយផ្ទាល់ពីរថ្ងៃក្នុងមួយសប្តាហ៍ ហើយចូលរួមក្នុងការសិក្សាតាមប្រព័ន្ធឌីជីថលបីថ្ងៃក្នុងមួយសប្តាហ៍ ដោយផ្អែកលើកាលវិភាគដែលបានកំណត់ ចាប់ផ្តើមពីថ្ងៃចន្ទ ទី5 ខែមេសា ឆ្នាំ 2021។ កាលវិភាគទាំងនេះត្រូវបានបង្កើតឡើងដើម្បីកំណត់ដោយសុវត្ថិភាពនូវចំនួនសិស្សនៅក្នុងសាលារៀនប្រចាំថ្ងៃនីមួយៗ និងជួយរក្សាការរក្សាគម្លាតសង្គមនៅគ្រប់ទីធ្លាសាលារៀនបានពេញមួយថ្ងៃ។

ខ្ញុំសូមលើកទឹកចិត្តឲ្យអ្នកមើលវីដេអូទាំងនេះស្តីពី ការត្រឡប់ទៅសាលារៀនវិញដោយសុវត្ថិភាព និង សាលារៀនដែលមានអនាម័យ និងល្អចំពោះសុខភាព និងចូលទៅកាន់គេហទំព័រ philasd.org/aes ដើម្បីស្វែងយល់បន្ថែមអំពីកម្រិតសុវត្ថិភាពជាច្រើនកម្រិតដែលយើងបានរៀបចំរួចរាល់ ដើម្បីការពារសុខភាព និងសុខុមាលភាពរបស់អ្នកទាំងអស់គ្នានៅក្នុងសាលារបស់យើង។ ប្រសិនបើអ្នកនៅមានសំណួរ អ្នកអាចទូរសព្ទមកខ្សែទូរសព្ទបន្ទាន់របស់យើងសម្រាប់គ្រួសារដែលនិយាយភាសាអង់គ្លេស តាមរយៈលេខ 215-400-5300ពីថ្ងៃចន្ទដល់ថ្ងៃ

សុក្រ ចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 4:30 ល្ងាច។ ខ្សែទូរសព្ទបន្ទាន់ជាភាសាផ្សេងទៀតអាចរកបាន[នៅទីនេះ]។

អ្នកនឹងទទួលបានតំណភ្ជាប់ទៅកាន់ការស្ទង់មតិស្តីពីការជ្រើសរើសគំរូការសិក្សានៅថ្ងៃអង្គារ សប្តាហ៍ក្រោយពីសាលា។ សូមកុំភ្លេចឆ្លើយតបមុនពេលការស្ទង់មតិបញ្ចប់នៅថ្ងៃទី23 ខែមីនា។ ប្រសិនបើអ្នកមិនបានឆ្លើយតបទៅនឹងការស្ទង់មតិទេ កូនរបស់អ្នកនឹងស្ថិត នៅក្នុងការសិក្សាតាមប្រព័ន្ធឌីជីថល 100% ដដែល។ គ្រួសារដែលជ្រើសរើសការសិក្សាបែបចម្រុះនឹងត្រូវបានទាក់ទងដោយសាលារៀនកូនៗ របស់ពួកគេនៅចន្លោះថ្ងៃទី 24-26 ខែមីនាឆ្នាំ2021 ទាក់ទងនឹងជំហានបន្ទាប់។ ដូចសព្វដងដែរ គឺក្រុមគ្រួសារដែលជ្រើសរើសការសិក្សាបែបចម្រុះអាចត្រឡប់ទៅការសិក្សាតាមប្រព័ន្ធឌីជីថល 100% បានគ្រប់ពេល។

សូមអរគុណចំពោះការបន្ត ភាពជាដៃគូរបស់អ្នក ខណៈពេលដែលយើងបន្តគាំទ្រដល់តម្រូវការការសិក្សារបស់អ្នកសិក្សាវ័យក្មេងខ្ចីបំផុតរបស់យើង។

ដោយសេចក្តីគោរពរាប់អាន

William R. Hite Jr., Ed.D.
ស្នងការ
មណ្ឌលសិក្សាធិការនៃក្រុង Philadelphia